ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.........................................................

## សេចក្តីប្រកាសព័ត៌មាន ស្តីពី
## សិក្ខាសាលាចាប់ផ្តើមអនុវត្តជាផ្លូវការនូវកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹង" ឆ្នាំ២០១៧ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលកូរ៉េ សម្រាប់ការស្រាវជ្រាវរួមគ្នាលើប្រធានបទស្តីពី "ទំនាក់ទំនងរវាងអត្រាប្តូរប្រាក់ និងអតិផរណានៅក្នុងសេដ្ឋកិច្ចកម្ពុជា"

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧

កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលកូរ៉េបានរៀបចំសិក្ខាសាលាចាប់ផ្តើមអនុវត្តជាផ្លូវការនូវកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹង" ឆ្នាំ២០១៧ សម្រាប់ការស្រាវជ្រាវរួមគ្នាលើប្រធានបទស្តីពី "ទំនាក់ទំនងរវាងអត្រាប្តូរប្រាក់ និងអតិផរណានៅក្នុងសេដ្ឋកិច្ចកម្ពុជា"។ ការស្រាវជ្រាវរួមគ្នានេះ ទទួលបានការគាំទ្រនិងឧបត្ថម្ភដោយកម្មវិធីភាពជាដៃគូផ្តល់ចំណេះដឹងរបស់ធនាគារកណ្តាលកូរ៉េ (BOK-KPP) ដែលនឹងផ្តល់ឱកាសឱ្យមន្ត្រីជំនាញធនាគារជាតិនៃកម្ពុជាបានសហការជាមួយអ្នកស្រាវជ្រាវនៃធនាគារកណ្តាលកូរ៉េ និងវិទ្យាស្ថានស្រាវជ្រាវការគ្រប់គ្រងសាកល (GMRI) របស់ប្រទេសកូរ៉េ ដើម្បីសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅពីទំនាក់ទំនងរវាងអត្រាប្តូរប្រាក់ និងអតិផរណានៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ដើម្បីចាប់ផ្តើមគម្រោងនេះ ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលកូរ៉េបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការស្រាវជ្រាវរួមគ្នា នៅឱកាសនោះផងដែរ។ ការស្រាវជ្រាវនេះគ្រោងនឹងបញ្ចប់និងផ្សព្វផ្សាយលទ្ធផល នៅខែធ្នូ ឆ្នាំ២០១៧ ខាងមុខ។

សិក្ខាសាលានេះត្រូវបានធ្វើឡើងក្រោមអធិបតីភាពរបស់ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា និងលោក Soon Won Chung ទីប្រឹក្សាជាន់ខ្ពស់នៃវិទ្យាស្ថានស្រាវជ្រាវការគ្រប់គ្រងសាកល ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និងគណៈប្រតិភូធនាគារកណ្តាលកូរ៉េ និងវិទ្យាស្ថានស្រាវជ្រាវការគ្រប់គ្រងសាកល។

ការស្រាវជ្រាវនេះនឹងបង្កើនឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលនៅមានកម្រិតនៅឡើយ ជាពិសេសទៅលើការប្រែប្រួលអត្រាប្តូរប្រាក់ និងការរក្សាស្ថិរភាពថ្លៃ។ លទ្ធផលនៃការស្រាវជ្រាវនឹងក្លាយជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំគោលនយោបាយសេដ្ឋកិច្ច និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ សំដៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព។ លើសពីនេះ ការស្រាវជ្រាវនេះនឹងរួមចំណែកពង្រឹងសមត្ថភាពរបស់មន្ត្រីធនាគារជាតិនៃកម្ពុជាលើការវិភាគ និងការប្រើប្រាស់ម៉ូឌែលសម្រាប់វាយតម្លៃនិងតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឱ្យកាន់តែប្រសើរឡើង។

ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧